# វ៉ាក់សាំង COVID-19

## អ្នកត្រូវដឹងក្បោះក្បាយ អំពីវ៉ាក់សាំង COVID-19*

### វាគឺមានសុវត្ថិភាព

**ការមានវ៉ាក់សាំង COVID-19 គឺត្រូវបានអនុញ្ញាតដោយ FDA និងបានឲ្យអនុសាសន៍ដោយ គណៈកម្មាធិការទីប្រឹក្សាស្តីពីការអនុវត្តន៍ចាក់ថ្នាំការពាររោគ របស់ CDC។**

វ៉ាក់សាំងបានប្រព្រឹត្តតាមជំហានដូចៗគ្នា សំរាប់ការពិសោធន៍ និងការទទួលស្គាល់ ដែលបានប្រើសំរាប់វ៉ាក់សាំងទាំងអស់។ វាបានផលិតឡើងយ៉ាងរហ័ស ប៉ុន្តែមិនដែលបានធ្វេសប្រហែសលើសុវត្ថិភាពទេ។ សំរាប់សេចក្តីពិស្តារថែមទៀត ស្តីពីសុវត្ថិភាពវ៉ាក់សាំង ទស្សនា mass.gov/COVIDVaccineSafety

### វាគឺឥតគិតថ្លៃ

**វ៉ាក់សាំង COVID-19 គឺកំពុងតែបានចាក់ឲ្យ ដោយឥតគិតថ្លៃ ទៅដល់បុគ្គលទាំងអស់ ដោយរដ្ឋាភិបាលសហព័ន្ធ។**

អ្នកអាចនឹងបានស្នើសុំ ព័ត៌មានធានារ៉ាប់រងរបស់អ្នក ប្រយោជន៍ឲ្យអ្នកចាក់ថ្នាំឲ្យអ្នក អាចចេញវិក្កយប័ត្រ ទៅក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នក។ តែយ៉ាងណាមិញ អ្នកនឹងមិនត្រូវបានទារថ្លៃឡើយ។ បើសិនអ្នកពុំមានការធានារ៉ាប់រងទេ អ្នកនៅតែមានសិទ្ធិទទួលវ៉ាក់សាំង ដោយឥតទារថ្លៃ។

### អ្នកអាចនឹងត្រូវការវ៉ាក់សាំងពីរ ដូស្ស ដើម្បីបានចាក់វ៉ាក់សាំងពេញលេញ

**ទំរាំនឹងអ្នកបានចាក់វ៉ាក់សាំងពេញលេញ អ្នកនៅតែអាចកើត និងចំឡងជំងឺ COVID-19 ទៀតដែរ។**

- **វ៉ាក់សាំង Pfizer៖** យ៉ាងហោច **21 ថ្ងៃ** ក្រោយពីដូស្សទីមួយ
- **វ៉ាក់សាំង Moderna៖** យ៉ាងហោច **28 ថ្ងៃ** ក្រោយពីដូស្សទីមួយ
- **វ៉ាក់សាំង Johnson & Johnson (Janssen)៖** តែ**មួយ**ដូស្សប៉ុណ្ណោះ

មិនមែនគ្រប់ៗគ្នានឹងបានចាក់វ៉ាក់សាំង នៅពេលអ្នកចាក់ឡើយ។ ហើយក្នុងខណៈយើងដឹង ថាវ៉ាក់សាំងកាត់បន្ថយករណី និងរោគសញ្ញាធ្ងន់ធ្ងរបានច្រើន យើងក៏កំពុងតែសិក្សាទៀត អំពីការការពារដែលវាផ្តល់។ ចូរបន្តពាក់ម៉ាស្ក, លាងដៃរបស់អ្នក, រក្សាគម្លាត, និងជៀសវាងក្រុមមនុស្សសូម្បីតែបន្ទាប់ពីអ្នក បានចាក់វ៉ាក់សាំងពេញលេញក៏ដោយ។

### ដូស្សទីពីររបស់អ្នក គួរតែបានចាក់នៅ ទីតាំងដូចគ្នា

**អ្នកត្រូវតែទទួលដូស្សទីពីររបស់អ្នក នូវវ៉ាក់សាំងដូចគ្នា នៅទីតាំងដូចនឹងលើកដំបូងរបស់អ្នកដែរ។**

ដូច្នេះហើយ មុននឹងចាកចេញពីការណាត់ជួប នៃការចាក់ដូស្សទីមួយរបស់អ្នក ត្រូវគ្រោងពេល ឬបញ្ជាក់របៀប ដើម្បីរៀបចំការណាត់ជួបរបស់អ្នក លើកក្រោយទៀត (សំរាប់ Pfizer និង Moderna)។

### រកឲ្យដឹងពេលវេលា ដែលអ្នកអាចបានចាក់វ៉ាក់សាំង នៅ mass.gov/covidvaccinephases

**រដ្ឋម៉ាស្សាជូសេត្ត កំពុងតែផ្តល់វ៉ាក់សាំង COVID-19 ជាដំណាក់កាលៗ ជាហូរហែ ដោយផ្តោតទៅលើភាពស្មើគ្នា និងសុវត្ថិភាព។**

ចិរវេលាផ្តោតលើការរក្សា សមត្ថភាពប្រព័ន្ធសុខាភិបាល, ការដោះស្រាយភាពអយុត្តិធម៌ ក្នុងការទទួលថែទាំសុខភាព និងបន្ទុកជំងឺ COVID-19, និងការពារប្រជាជនដែលងាយរងគ្រោះ។ ដំណាក់កាលនិមួយៗ មានក្រុមជាអាទិភាព នៅក្នុងវា។ សំរាប់ក្រុមជាអាទិភាព បានទាន់បច្ចុប្បន្នភាព យ៉ាងទៀងទាត់ និងការងារមានសិទ្ធិចាក់ និងលក្ខណៈសុខភាព ទស្សនា mass.gov/COVIDVaccinePhases

* ព័ត៌មាននេះបានទាន់បច្ចុប្បន្នភាព ចុងក្រោយនៅ 3/15/2021 និងអនុវត្តចំពោះវ៉ាក់សាំង Moderna និង Pfizer និង Johnson & Johnson (Janssen)។

សំរាប់ព័ត៌មានថែមទៀត ស្តីពីវ៉ាក់សាំង COVID-19, ដំណាក់កាល, និងច្រើនទៀត ទស្សនា mass.gov/COVIDVaccinePhases